CITY OF LONGBEACH

PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 18 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ រិក ឌី ឡា ទ័រ (Rick de la Torre) មន្ត្រីព័ត៌មានសហគមន៍ នៃនាយកដ្ឋានសេវាអភិវឌ្ឍន៍ ឡុងប៊ិច, 562.570.7174, Rick.Delatorre@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# មជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាតិ ឡុងប៊ិច នៅសាលាក្រុង ចាប់ផ្តើមបម្រើសេវាជូនអតិថិជន ដោយផ្ទាល់ ក្នុងកម្រិតកំណត់មួយ ។

ឡុងប៊ិច, CA - មជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍន៍ នៃសាលាក្រុងឡុងប៊ិច នៅជាន់ ទី 2 នៃអគារសាលាក្រុង ឥឡូវនេះ បើកបម្រើសេវាជូន តាមការណាត់ជួប ទុកជាមុន ក្នុងដែនកម្រិតមួយ សម្រាប់តែលិខិតអនុញ្ញាតរហ័ស ពាក់ព័ន្ធនឹង គម្រោងសាងសង់ ខ្នាតតូច ។ ការណាត់ជួប ទុកជាមុន នៅថ្ងៃដដែល អាចធ្វើទៅបាន នៅពេលមានចន្លោះពេល (ការដើរចូលមកជួបដោយគ្មានការណាត់ជួបទុកជាមុន នឹងមិនត្រូវបានអនុញ្ញាតនោះទេ) ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) «ការបើកដំណើរការមជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាតរបស់យើង ឡើងវិញ ដោយមានការកំណត់កម្រិត និងប្រកបដោយសុវត្ថិភាព គឺជាជំហ៊ានវិជ្ជមានមួយទៀត ដែលយើងសម្រេចបាន ខណៈដែលការឆ្លងរាតត្បាត COVID-19 ជាសាកលបន្តថមថយចុះ ។» «យើងខ្ញុំដឹងថា អតិថិជនមកស្នើសុំលិខិតអនុញ្ញាតរបស់យើង ដូចជា ម្ចាស់ផ្ទះ និងអ្នកម៉ៅការ បានរង់ចាំឱកាស មកដោយផ្ទាល់ ដើម្បីចាប់ផ្តើម ឬ បន្តការងារគម្រោងផ្សេងៗ របស់ពួកគេ ហើយការបើកបម្រើសេវា ឡើងវិញ ដោយមានការកម្រិតនេះ នឹងផ្តល់ក្តីសង្ឃឹមដល់ពួកគេហើយ ។»

ការណាត់ជួបផ្ទាល់ ទុកជាមុន អាចធ្វើទៅបាន ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 1 ដល់ 3:30 រសៀល ។ ដើម្បីទទួលបានព័ត៌មានលំអិត និងធ្វើការណាត់ជួប ទុកជាមុន សូមចូលទៅ longbeach.gov/permits ។

**ភ្ញៀវរបស់មជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាត គួរយល់ដឹង អំពីគោលការណ៍ណែនាំ និងនីតិវិធី ដូចខាងក្រោមនេះ៖**

- អ្នកដែលមានការណាត់ជួប ទុកជាមុន ដើម្បីចូលអគារសាលាក្រុង ត្រូវពាក់របាំងមុខ ហើយគោរពតាម គោលការណ៍ណែនាំសុវត្ថិភាព COVID-19 រួមទាំង ការកំណត់កម្រិតតាមតំបន់ប្រជាសាស្ត្រ (occupancy restrictions) ។
- ការណាត់ជួបទាំងអស់ គឺសម្រាប់តែគម្រោងសាងសង់ ដែលមានគុណវុឌ្ឍន៍ សម្រាប់លិខិតអនុញ្ញាត រហ័សប៉ុណ្ណោះ ។ ឧទាហរណ៍ រួមមាន ការប្តូរម៉ាស៊ីនកម្តៅទឹក, សេវាអគ្គិសនី ឬការតម្លើងកម្រិតប្រព័ន្ធកម្តៅ, ការប្តូរបង្អួច និងប្រក់ដំបូលថ្មី ។ សូមមើល ព្រឹត្តិប័ត្រព័ត៌មាន អំពីសេវាផ្ត

ល់លិខិតអនុញ្ញាត IB-058 លឿន សម្រាប់បញ្ជីគម្រោងសាងសង់ ខ្នាតតូច ដែលមានគុណវុឌ្ឍន៍ សម្រាប់សេវានេះ ។

- អតិថិជនគួរត្រៀមលក្ខណ: ក្នុងការដាក់ឯកសារពាក់ព័ន្ធទាំងអស់ ជាទម្រង់ឯកសារឌីជីថល PDF នៅក្នុងឧបករណ៍ផ្ទុកទិន្នន័យ (USB) ។
- សេវា តាមអ៊ីនធឺណែត នឹងបន្តដំណើរការ សម្រាប់ប្រភេទគម្រោងផ្សេងៗ ទៀត ដែលមិនអាចទទួលសេវា ដោយការមកដាក់ពាក្យដោយផ្ទាល់បាន ។

«យើងខ្ញុំមានក្តីរីករាយ និងរំភើប ដែលយើងខ្ញុំចាប់ផ្តើមធ្វើការ ដោយផ្ទាល់ ជាថ្មីម្តងទៀត ជាមួយអតិថិជន នៅពេលយើងខ្ញុំចាប់ផ្តើមត្រឡប់មកបំពេញប្រតិបត្តិការ ជាធម្មតាឡើងវិញ ។» «ការកែសម្រួលទៅលើប្រព័ន្ធឌីជីថលរបស់យើងខ្ញុំ និងការកែប្រែ ផ្សេងៗទៀត ដែលយើងខ្ញុំបានធ្វើ និងបន្តធ្វើ ដើម្បីធ្វើឱ្យសេវា ប្រសើរឡើង, ដោយគិតចាប់ពីពេលដាក់ពាក្យស្នើសុំដំបូង ដល់ពេលពិនិត្យមើលប្លង់ រហូតដល់ពេលចេញលិខិតអនុញ្ញាត, នឹងជួយយើងខ្ញុំឱ្យអាចរក្សាបាន ការប្តេជ្ញាចិត្ត ក្នុងការកសាងឡុងប៊ិចឱ្យកាន់តែប្រសើរឡើង ។»

ឡុងប៊ិច បានចាត់វិធានការមួយចំនួន ក្នុងការកែលំអ រយៈពេលឆ្លើយតប ក្នុងការផ្តល់លិខិតអនុញ្ញាត រួមទាំង ការបើកមជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាត ឡើងវិញ, ដោយពាក្យស្នើសុំ សម្រាប់គម្រោង ខ្នាតតូចដែលនៅសល់ ទទួលបានការឆ្លើយតប ក្នុងរយៈពេល កាន់តែឆាប់រហ័សជាមុន ។ ព័ត៌មានបន្ថែមទៀត អំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងបុព្វហេតុ ដែលនាំឱ្យរយៈពេលឆ្លើយតប កើនច្រើនឡើង អាចរកបាន នៅទីនេះ ។

**អំពីសេវាអភិវឌ្ឍន៍ ឡុងប៊ិច**

ដោយបម្រើសេវាជូន ប្រជាពលរដ្ឋ ធុរកិច្ច និងសហគមន៍ ជាទូទៅ, នាយកដ្ឋានសេវាអភិវឌ្ឍន៍ ឡុងប៊ិច កំណត់បទដ្ឋាន សម្រាប់គុណភាពខ្ពស់, ការធ្វើផែនការក្រុង ប្រកបដោយនវានុវត្តន៍ និង កិច្ចខិតខំប្រឹងប្រែង យ៉ាងរស់រវើក ដែលបង្កើតសហគមន៍ ប្រកបដោយវឌ្ឍនភាព និងនិរន្តរភាព កានតែប្រសើរឡើង នៅក្នុងទីក្រុង ។

សម្រាប់ព័ត៌មាន បន្ថែមទៀត សូមចូលទៅ longbeach.gov/lbds ។ សូមតាមយើងខ្ញុំ នៅលើបណ្តាញសង្គមដើម្បីទទួលបានព័ត៌មានចុងក្រោយបំផុតនានា ៖ Facebook, Twitter និង Instagram ។

**អំពីទីក្រុងឡុងប៊ិច**

មានប្រជាជនប្រមាណ 470,000 នាក់ សាលាក្រុងឡុងប៊ិច ដែលបានទទួលបានពានរង្វាន់ និងច្នៃប្រឌិតថ្មីជាច្រើន បានផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកនៃទីក្រុងធំមួយ ខណៈពេលដែលរក្សាបាននូវលក្ខណៈភាពជាបុគ្គល និងមានចម្រុះដោយភូមិស្ថានផ្សេងៗគ្នាផ្តុំគ្នានៅតាមបណ្តោយឆ្នេរសមុទ្រ California។ ក្នុងនាមជាទីក្រុងដែលផ្តល់សេវាកម្មពេញលេញ, ទីក្រុងឡុងប៊ិច ជាទីតាំងនៃសារមន្ទីរ និងមហោស្រពជាច្រើន ដូចជា Queen Mary, Aquarium of the Pacific, និងមានកន្លែងជាច្រើនទៀត មណ្ឌលសាលារៀនដែលត្រូវបានគេវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច និងកំពង់ផែឡុងប៊ិច។ មន្ទីរសាលាក្រុង បានឈ្នះពានរង្វាន់ជាច្រើន ផ្សេងទៀតដូចជាសុខភាព សួនឧទ្យាន កំពង់ផែកំសាន្ត និងសេវាកម្មអភិវឌ្ឍន៍ និងផ្សេងៗទៀត។ ទីក្រុង ក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យដែលត្រូវបានគេវាយតម្លៃខ្ពស់, មានកន្លែងកសិដ្ឋានចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រពីរកន្លែង, មន្ទីរពេទ្យប្រាំ កន្លែង, ទីវាលហ្វឹកហាត់វាយកូនហ្គោលប្រាំ កន្លែង, សួនច្បារ 171, ឆ្នេរសមុទ្ររាប់សិបម៉ាយល៍, កំពង់ផែសម្រាប់លំហែកំសាន្តជាច្រើនកន្លែង, គន្លងផ្លូវជិះកង់ និងកម្មវិធីចែកចាយកង់។

CITY OF LONGBEACH

# PRESS RELEASE

សម្រាប់ព័ត៌មាន បន្ថែមទៀត អំពីទីក្រុងឡុងប៊ិច សូមចូលទៅ longbeach.gov ។ សូមតាមយើងខ្ញុំ នៅលើបណ្តាញសង្គមដើម្បីទទួលបានព័ត៌មានចុងក្រោយបំផុតនានា ៖ Facebook, Twitter, Instagram និង YouTube ។

###

REMINDER

- Make sure the document has the City of Long Beach/Press Release heading
- Make sure the document does not include the language at the bottom about Google translations
- The document name should be a summary of the title of the press release, followed by an underscore, and then the language (e.g. Three New Testing Sites Announced_Spanish)